**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |

៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៥- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

៦- តំណាងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាសមាជិក

៧- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៨- តំណាងក្រសួងពាណិជ្ជកម្ម ជាសមាជិក

៩- តំណាងក្រសួងទេសចរណ៍ ជាសមាជិក

១០- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

១១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក

១២- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាសមាជិក

១៣- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ជាសមាជិក

១៤- អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ជាសមាជិក

១៥- អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ជាសមាជិក

១៦- អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ ជាសមាជិក

១៧- អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ជាសមាជិក

**ប្រការ ២.-**

គណៈកម្មការខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីត្រៀមរៀបចំខ្លឹមសារនានាសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦
- ពិភាក្សា និងសម្របសម្រួលជាមួយភាគីថៃ ក្នុងការរៀបចំខ្លឹមសារកិច្ចប្រជុំឱ្យបានសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងកិច្ចការផ្សេងៗទៀតដែលបម្រើឱ្យកិច្ចប្រជុំ
- ក្នុងការត្រៀមរៀបចំខ្លឹមសារខាងលើនេះ ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈកម្មការមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំពិភាក្សាការងារសម្រាប់រៀបចំកិច្ចប្រជុំនេះ តាមការចាំបាច់
- ប្រធានគណៈកម្មការមានសិទ្ធិស្នើសុំរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្កើតក្រុមការងារសម្រាប់គាំទ្រដល់កិច្ចប្រជុំនេះតាមការចាំបាច់
- អនុប្រធាន និងសមាជិកគណៈកម្មការត្រូវចូលរួមកិច្ចប្រជុំ និងទទួលភារកិច្ចនានាតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៣.-**

គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រាររបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់ខ្លួន និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់គណៈកម្មការ និងសម្រាប់រៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦នេះ។

**ប្រការ ៤.-**

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦ ត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ និងបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ